# រដ្ឋមន្ត្រីការបរទេសជប៉ុន ៖ កម្ពុជា ជាប្រទេសមួយដែលដក់ជាប់ក្នុងអារម្មណ៍ខ្ញុំ



លោក Taro Kono រដ្ឋមន្ត្រីការបរទេសជប៉ុន មកបំពេញទស្សនកិច្ចនៅកម្ពុជានាថ្ងៃ០៨ ខែមេសានេះ

ភ្នំពេញ ៖ នៅក្នុងឱកាសដែល លោក តារ៉ូ កូណូ (Taro Kono) រដ្ឋមន្ត្រីការបរទេស នៃប្រទេសជប៉ុន អញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី៨ ខែមេសា ឆ្នាំ ២០១៨ នេះ លោកបានផ្តល់បទសម្ភាសន៍មួយ

តទៅទំព័រ ក៤

តមកពីទំព័រ ក១

## រដ្ឋមន្ត្រីការបរទេស...

តាមរយៈសារអេឡិចត្រូនិក (អ៊ីមែល) ជាមួយកម្ពុជាថ្មី ពាក់ព័ន្ធទៅនឹងប្រធានបទ «ការវិវត្តនៃទំនាក់ទំនងការទូត រវាងប្រទេសកម្ពុជានិងជប៉ុន និងទស្សនវិស័យរបស់ប្រទេសជប៉ុន ចំពោះការបោះឆ្នោតនៅកម្ពុជា ក្នុងឆ្នាំ២០១៨នេះ» ដែលមានខ្លឹមសារដូចខាងក្រោមនេះ៖

កម្ពុជាថ្មី៖ ឆ្នាំនេះគឺជាខួបអនុស្សាវរីយ៍៦៥ឆ្នាំ នៃការបង្កើតទំនាក់ទំនងការទូតរវាងជប៉ុន និងកម្ពុជា។ តើលោករដ្ឋមន្ត្រីការបរទេសជប៉ុន វាយតម្លៃយ៉ាងណាអំពីការវិវត្តនៃទំនាក់ទំនងការទូត រវាងប្រទេសយើងទាំងពីរ ?

លោក តារ៉ូ កូណូ ៖ ក្នុងឱកាសខួបអនុស្សាវរីយ៍ ៦៥ឆ្នាំនៃទំនាក់ទំនងការទូតរវាងជប៉ុននិងកម្ពុជា ខ្ញុំមានសេចក្តីសប្បាយរីករាយ ដែលបានបំពេញទស្សនកិច្ច នៅព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជារដ្ឋមន្ត្រីការបរទេសជប៉ុន។

នៅពេលបច្ចុប្បនេះប្រទេសកម្ពុជាកំពុងត្រូវបានអភិវឌ្ឍគួរឲ្យកត់សម្គាល់ ប្រកបទៅដោយកម្លាំងយុវជនដ៏សកម្មនិងទីក្រុងដ៏រស់រវើក។តំណាងឲ្យប្រទេសជប៉ុន ដែលបានចូលរួមក្នុងការស្តារនិងអភិវឌ្ឍប្រទេសកម្ពុជាតាំងពីដំណើរការកសាងសន្តិភាពខ្ញុំសូមសម្តែងអំណរសាទរចំពោះប្រទេសកម្ពុជា ក៏ដូចជាប្រជាជនកម្ពុជា ក្នុងការសម្រេចបាននូវការអភិវឌ្ឍ ដែលមានដូចសព្វថ្ងៃនេះ។

កន្លងមកនេះក្រុមហ៊ុនជប៉ុន មានប្រមាណ១៨០ក្រុមហ៊ុន បាននិងកំពុងធ្វើការជាមួយប្រជាជនកម្ពុជាជាច្រើននាក់ នៅក្នុងវិស័យផ្សេងៗ ចាប់តាំងពីឧស្សាហកម្មធុនស្រាល, ផលិតកម្មគ្រឿងម៉ាស៊ីនដ៏តូចល្អិត, ពាណិជ្ជកម្ម និងសេវាកម្ម។ ទំហំពាណិជ្ជកម្មរវាងប្រទេសយើងទាំងពីរ ក៏បានកើនឡើងដល់ ១,៦៤០លានដុល្លារសហរដ្ឋអាមេរិក នៅឆ្នាំ២០១៦ គឺច្រើនជាង១០ដងបើប្រៀបធៀបនៅនឹងឆ្នាំ១៩៩៣។

ទំនាក់ទំនងរវាងប្រទេសយើងទាំងពីរ ក៏កាន់តែមានការរីកចម្រើនឡើង គួរឲ្យកត់សម្គាល់ផងដែរ។ ក្នុងឆ្នាំ២០១៦ជើងហោះហើរត្រង់ បានចាប់ផ្តើមដំណើរការជាលើកទីមួយ រវាងប្រទេសយើងទាំងពីរ។ ជារៀងរាល់ឆ្នាំប្រជាជនជប៉ុនប្រមាណ ២០ម៉ឺននាក់បានមកទស្សនានៅប្រទេសកម្ពុជាជាពិសេសប្រាសាទនានានៃតំបន់អង្គរ ក្នុងខេត្តសៀមរាប ហើយចំនួនប្រជាជនកម្ពុជា ដែលធ្វើដំណើរទៅប្រទេសជប៉ុនក៏មានការកើនឡើងដែរជាពិសេសនៅចុងខែមីនាឆ្នាំនេះមានប្រជាជនកម្ពុជា ជាច្រើនបានទៅទស្សនាផ្កាសាគូរ៉ា នៅប្រទេសជប៉ុន។

រដ្ឋាភិបាលជប៉ុនក៏បានយកចិត្តទុកដាក់ ក្នុងការជំរុញការផ្លាស់ប្តូរ ទំនាក់ទំនងរវាងប្រជាជននៃប្រទេសយើងទាំងពីរជាពិសេសទំនាក់ទំនងរវាងយុវជននិងយុវជនដែលជាសសរទ្រូងរបស់ប្រទេសជាតិនាពេលអនាគត។ដាក់ស្តែងកម្មវិធីផ្លាស់ប្តូរយុវជន «JENESYS» ដែលបានបង្កើតនៅឆ្នាំ២០០៧នាំឲ្យយុវជនកម្ពុជានិងជប៉ុនប្រមាណ២,៦០០នាក់បានផ្លាស់ប្តូរទស្សនកិច្ច រវាងប្រទេសយើងទាំងពីរ។

ចាប់តាំងពីឆ្នាំ១៩៩២មករដ្ឋាភិបាលជប៉ុនក៏បាននិងកំពុង សហការជាមួយកម្ពុជាក្នុងវិស័យបណ្តុះបណ្តាលធនធានមនុស្សនិងបានផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជាជាង ១០០០នាក់មកហើយ។

ខ្ញុំសប្បាយរីករាយ ដែលបានឃើញអតីតនិស្សិតទទួលបានអាហារូបករណ៍ទាំងនោះ បាននឹងកំពុងចូលរួមចំណែក យ៉ាងសកម្មក្នុងវិស័យផ្សេងៗ ក្នុងនោះមានសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យធំៗបីគឺ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ,សាកលវិទ្យាល័យជាតិគ្រប់គ្រងនិងវិទ្យាស្ថានបច្ចេកវិទ្យានៃកម្ពុជា។

ក្នុងឆ្នាំនេះ ដែលជាខួប៦៥ឆ្នាំ នៃការបង្កើតទំនាក់ទំនងការទូត រវាងជប៉ុននិងកម្ពុជាមានកម្មវិធីអបអរសាទរជាច្រើន។នាខែកុម្ភៈមហោស្រពគីហ្សូណាជប៉ុន-កម្ពុជា ២០១៨លើកទី៧ត្រូវបានរៀបចំឡើងនៅកម្ពុជាទទួលបានអ្នកចូលរួមប្រហែល ២៣,០០០នាក់។ នៅប្រទេសជប៉ុនវិញនៅខែឧសភាខាងមុខនេះ មហោស្រពកម្ពុជាលើកទី ៤នឹងប្រព្រឹត្តទៅនៅសួនច្បារ Yoyogi ក្នុងទីក្រុងតូក្យូ។

ដូចដែលបានរៀបរាប់ខាងលើទំនាក់ទំនងជប៉ុននិងកម្ពុជាមានការផ្លាស់ប្តូរយ៉ាងសកម្មលើគ្រប់វិស័យ រួមមាននយោបាយ,សេដ្ឋកិច្ច,ការទូត,វប្បធម៌,សង្គម ។ល។ ខ្ញុំសង្ឃឹមថាតាមរយៈទស្សនកិច្ចរបស់ខ្ញុំលើកនេះនឹងនាំឲ្យទំនាក់ទំនងដ៏អស្ចារ្យរបស់យើង នឹងមានការវិវឌ្ឍទៅមុខ កាន់តែខ្លាំងបន្ថែមទៀត។

ប្រទេសកម្ពុជា ជាប្រទេសមួយដែលដក់ជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំ ដោយសារឪពុកខ្ញុំ Yohei-Kono ធ្លាប់បានមកធ្វើទស្សនកិច្ចនៅកម្ពុជាក្នុងនាមជាឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីការបរទេសជប៉ុន កាលពី២៣ឆ្នាំមុនគឺពេលដែលអ៊ុនតាក់ ទើបតែបានបញ្ចប់សកម្មភាពថែរក្សាសន្តិភាព (PKO) ហើយកម្ពុជា បានកសាងប្រទេសឡើងវិញជាបន្តបន្ទាប់។ នៅពេលនោះឪពុកខ្ញុំបានប្រកាសថាប្រទេសជប៉ុននឹងចូលរួមចំណែក យ៉ាងសកម្មជាមួយកម្ពុជា ដើម្បីកសាងប្រទេសឡើងវិញ។ដោយសារមូលហេតុខាងលើនេះខ្ញុំសប្បាយរីករាយចំពោះទស្សនកិច្ចលើកនេះ។

កម្ពុជាថ្មី៖ តើរដ្ឋាភិបាលជប៉ុនមានចក្ខុវិស័យបែបណាចំពោះសហប្រតិបត្តិការ ក្នុងការអភិវឌ្ឍជាមួយកម្ពុជា ?តើអ្វីជាអាទិភាព នៃកិច្ចសហប្រតិបត្តិការជប៉ុននិងមូលហេតុ នៃការផ្តល់អាទិភាព ?

លោក តារ៉ូ កូណូ៖ ប្រទេសជប៉ុនបាននិងកំពុងចូលរួមសហការ ក្នុងដំណើរការសន្តិភាពការស្តារនិងអភិវឌ្ឍរបស់កម្ពុជា។ គម្រោងសហប្រតិបត្តិការទីមួយរបស់ជប៉ុន ក្រោយសង្គ្រាមស៊ីវិលរបស់កម្ពុជាគឺការជួសជុលស្ពានជ្រោយចង្វារដែលត្រូវបានព្រះករុណាព្រះបរមរតនកោដ្ឋទ្រង់ប្រទានឈ្មោះ «ស្ពានមិត្តភាពកម្ពុជា-ជប៉ុន»។ ស្ពាននេះកំពុងត្រូវបានជួសជុលដើម្បីឆ្លើយតបនឹងកំណើនចរាចរណ៍ព្រមទាំងថែរក្សានិមិត្តរូបនៃមិត្តភាពរវាងប្រទេសយើងទាំងពីរផងដែរ។

គម្រោងសហប្រតិបត្តិការជប៉ុនបានអនុវត្តនៅលើវិស័យជាច្រើនដូចជាប្រព័ន្ធទឹកស្អាត,ការគាំពារមាតានិងទារក,ការអប់រំ,ការដឹកជញ្ជូននិងចរាចរណ៍,កសិកម្ម,ការបោសសម្អាតមីន,ការរៀបចំបរិស្ថានជុំវិញ,ការវិនិយោគ,ការរៀបចំប្រព័ន្ធច្បាប់ដូចជាក្រមរដ្ឋប្បវេណីនិងក្រមនីតិវិធីរដ្ឋប្បវេណីនិងការបណ្តុះបណ្តាលធនធានមនុស្ស។

ចក្ខុវិស័យរបស់ជប៉ុន ផ្តោតទៅលើវិធានការរៀបចំប្រព័ន្ធដ៏សំខាន់ក្នុងសង្គម និងការកាត់បន្ថយភាពក្រីក្រ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងកម្ពុជា និងប្រទេសក្នុងតំបន់។

ក្រោយមកដោយមានការចូលរួមពីជប៉ុននិងសហគមន៍អន្តរជាតិកម្ពុជាសម្រេចកំណើនសេដ្ឋកិច្ចបាន៧% ក្នុងមួយឆ្នាំគិតជាមធ្យមនិងកាត់បន្ថយអត្រាក្រីក្រ បានយ៉ាងច្រើនផងដែរ។ ម៉្យាងវិញទៀតពេលបច្ចុប្បន្ននេះប្រទេសកម្ពុជាកំពុងប្រឈមបញ្ហានានាដែលបណ្តាលមកពីនគរូបនីយកម្មជាពិសេសរាជធានីភ្នំពេញនិងបញ្ហាមួយចំនួនទៀតដូចជាគម្លាតរវាងទីក្រុងនិងជនបទ។ ប្រទេសជប៉ុនក៏យល់ឃើញ ពីសារៈសំខាន់នៃការដោះស្រាយបញ្ហាទាំងនេះហើយនិងបន្តសហការក្នុងការកែលម្អប្រព័ន្ធឡូជីស្ទិក, ការពង្រឹងមុខងារទីក្រុងនិងការអប់រំព្រមទាំងការបណ្តុះបណ្តាលធនធានមនុស្ស។ រដ្ឋាភិបាលកម្ពុជា កំពុងខិតខំធ្វើការដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមដោយឆ្ពោះទៅរកគោលដៅក្លាយជាប្រទេសមានចំណូលមធ្យម កម្រិតខ្ពស់នៅឆ្នាំ២០៣០។

ប្រទេសជប៉ុននឹងបន្តសហការជាមួយកម្ពុជាទៅតាមគោលនយោបាយសហប្រតិបត្តិការអភិវឌ្ឍដែលផ្តោតលើចំណុចសំខាន់ៗដូចតទៅ៖ទី១.ការលើកស្ទួយឧស្សាហកម្ម ដូចជាការរៀបចំហេដ្ឋារចនាសម្ព័ន្ធទី២.ការបង្កើនគុណភាពនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ដូចជាវិស័យសុខាភិបាលនិងប្រព័ន្ធទឹកស្អាត និងទី៣.ការសម្រេចឲ្យមានសង្គម ប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងអភិបាលកិច្ចល្អ។

កម្ពុជាថ្មី ៖ សូមលោករដ្ឋមន្ត្រីបង្ហាញពីទស្សនវិស័យរបស់ជប៉ុន ចំពោះការបោះឆ្នោតនៅកម្ពុជា។ តើការបោះឆ្នោតលើកនេះ អាចមានឥទ្ធិពលដល់ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងជប៉ុនទេ ?

លោក តារ៉ូ កូណូ ៖ ក្នុងនាមជាមិត្តដែលបាននិងកំពុងចូលរួមក្នុងការកសាងប្រទេសដោយឈរលើលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជា ប្រទេសជប៉ុនសង្ឃឹមថា ការបោះឆ្នោតដែលរៀបចំដោយរដ្ឋាភិបាលកម្ពុជា នៅខែកក្កដាឆ្នាំនេះ នឹងឆ្លុះបញ្ចាំងពីមតិប្រជាជន បានយ៉ាងពិតប្រាកដ។

យើងខ្ញុំក៏សង្ឃឹមផងដែរថាតាមរយៈការបោះឆ្នោតនៅខែកក្កដាខាងមុខនេះកម្ពុជានឹងរៀបចំស្ថានភាពមួយដ៏សមស្របដែលកម្ពុជាអាចអភិវឌ្ឍប្រទេសឆ្ពោះទៅរកប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ដោយមានការរួបរួមគ្នា ពីសំណាក់ប្រជាជនទាំងអស់។

ខ្ញុំសូមជូនពរ ដល់ទំនាក់ទំនងរវាងប្រទេសយើងទាំងពីរសូមឲ្យបន្តរីកចម្រើននិងស៊ីជម្រៅបន្ថែមទៀត។

គួររម្លឹកផងដែរថា ក្នុងអំឡុងទស្សនកិច្ចរបស់លោក តារ៉ូ កូណូ នៅប្រទេសកម្ពុជា លោកនឹងអញ្ជើញចូលជួបសម្តែងការគួរសមជាមួយសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា និងជួបពិភាក្សាទ្វេភាគី ជាមួយលោក ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

ជាងនេះទៅទៀត លោក តារ៉ូ កូណូ និង លោក ប្រាក់ សុខុន នឹងចុះហត្ថលេខាលើលិខិតប្តូរសារ និងកំណត់ហេតុ នៃការពិភាក្សា ស្តីពីការផ្តល់ហិរញ្ញប្បទានរបស់រដ្ឋាភិបាលជប៉ុន មកកាន់រាជរដ្ឋាភិបាលកម្ពុជាក្រោមអធិបតីភាពរបស់សម្តេចតេជោ ហ៊ុន សែន មានដូចជា៖

ទី១. ហិរញ្ញប្បទានឥតសំណងជប៉ុន ដែលមានទឹកប្រាក់សរុបចំនួន ៥០០លានយ៉េន សម្រាប់អនុវត្តន៍គម្រោងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនៅកម្ពុជា

ទី២. ឥណទានសម្បទានជប៉ុន ដែលមានទឹកប្រាក់សរុបចំនួន ៩.២១៦ លានយ៉េន សម្រាប់អនុវត្តន៍គម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយអគ្គិសនី នៅរាជធានីភ្នំពេញ ជំហានទី២៕

បូរិន